# សុន្ទរកថារបស់ លោក MATSUMOTO Izumi លេខាទី២នៃស្ថានទូតជប៉ុនប្រចាំកម្ពុជា
# ថ្លែងក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់ជាផ្លូវការនូវអគារសិក្សា
# នៅសាលាបឋមសិក្សាឈើទាលជ្រុំ ក្នុងវាលវែង ខេត្តពោធិ៍សាត់

- សូមក្រាបថ្វាយបង្គំ ព្រះសង្ឃ គ្រប់ព្រះអង្គ
- សូមគោរព ភ្ញៀវកិត្តិយសទាំងអស់

ថ្ងៃនេះ ខ្ញុំសប្បាយរីករាយណាស់ដែលបានចូលរួមអបអរសាទរក្នុងពិធីសម្ពោធអគារសិក្សាថ្មីនៅសាលាបឋមសិក្សាឈើទាលជ្រុំដោយមានវត្តមានរបស់ភាគីពាក់ព័ន្ធទាំងអស់។

ខ្ញុំសូមសម្តែងចំណាប់អារម្មណ៍តំណាងឲ្យស្ថានទូតជប៉ុននៅកម្ពុជា។

ការអប់រំកុមារគឺជាកត្តាសំខាន់សម្រាប់អនាគតរបស់កម្ពុជា។ រដ្ឋាភិបាលជប៉ុនគាំទ្រវិស័យអប់រំនៅកម្ពុជាតាមរូបភាពផ្សេងៗរួមទាំងគម្រោងគូសាណូណិនេះផងដែរ។

អគារសិក្សានេះត្រូវបានសាងសង់តាមរយៈជំនួយគូសាណូណិ។ នេះគឺជាសាលាទី១២ដែលត្រូវបានសាងសង់ក្នុងខេត្តពោធិ៍សាត់។

ក្នុងគម្រោងនេះ រដ្ឋាភិបាលជប៉ុនបានផ្តល់ជូននូវអគារសិក្សា៤បន្ទប់ បន្ទប់ទឹក២ ធុងស្តុកទឹកនិងបរិក្ខារសិក្សាដូចជា៖ តុ កៅអី ជាដើម។ ខ្ញុំសប្បាយរីករាយណាស់ដែលកុមារច្រើនជាង២២០នាក់អាចសិក្សាបានដោយសុវត្ថិភាព។

តំណាងឲ្យរដ្ឋាភិបាលជប៉ុន ខ្ញុំសង្ឃឹមថា ជំនួយនេះនឹងត្រូវបានថែទាំយ៉ាងល្អ និងប្រើប្រាស់ឲ្យបានយូរអង្វែង ហើយនឹងក្លាយជានិមិត្តរូបនៃមិត្តភាពរវាងកម្ពុជា និងជប៉ុន។

ជាទីបញ្ចប់ ខ្ញុំសូមអរគុណជាថ្មីម្តងទៀតដល់មន្ទីរអប់រំខេត្តពោធិ៍សាត់ និងលោក-អ្នកទាំងអស់ដែលបានអនុវត្តគម្រោងនេះ។ ខ្ញុំក៏សូមជូនពរឲ្យមិត្តភាពរវាងកម្ពុជា និងជប៉ុន មានការរីកចម្រើនមួយកម្រិតទៀត៕

**សូមអរគុណ!**